ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



SOCIAL PROTECTION IN CAMBODIA

# ការវាយតម្លៃលើការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមកម្ពុជា

# Review of the Cambodian National Social Protection Policy Framework

**សង្ខេបគោលនយោបាយ: លេខ ៨**

ឯកសារសង្ខេបគោលនយោបាយនេះ បង្ហាញដោយសង្ខេបពី លទ្ធផលនៃការវាយតម្លៃពាក់កណ្ដាលអាណត្តិលើការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលបានបញ្ចប់ នៅខែមិថុនា ឆ្នាំ២០២២

**POLICY BRIEF VOL.8**

This policy brief summarizes the results of the mid-term review of the National Social Protection Policy Framework (NSPPF) 2016-2025 conducted in June 2022

International Labour Organization
JOINT SDG FUND
Co-funded by the European Union

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែសីហា ឆ្នាំ២០២៣

# ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម រហូតមកដល់ពេលបច្ចុប្បន្ន

**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បាននាំមកនូវការបោះមួយជំហានទៅមុខ ក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។** ក្របខណ្ឌគោលនយោបាយនេះជាមូលដ្ឋានសម្រាប់ការធ្វើនិម្មាបនកម្មប្រព័ន្ធគាំពារសង្គមកម្ពុជា ដោយបានដាក់ចេញនូវគោលនយោបាយជាក់លាក់សម្រាប់អនុវត្តប្រកបដោយភាពប្រាកដប្រជា។ ក្របខណ្ឌគោលនយោបាយនេះជាទស្សនាទានលើកដំបូង ដែលបង្កើតឱ្យមានប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ដែលជាសសរស្តម្ភនៃប្រព័ន្ធគាំពារសង្គម។ គន្លឹះនៃភាពជោគជ័យក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម គឺការរៀបចំឱ្យមានរចនាសម្ព័ន្ធអភិបាលកិច្ចជាក់លាក់ ដើម្បីគាំទ្រដល់ភាពស៊ីសង្វាក់គ្នារវាងកម្រិតគោលនយោបាយ និងកម្រិតប្រតិបត្តិការ។

**ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ជាកាតាលីករគាំទ្រដ៏សំខាន់ ក្នុងការជំរុញសន្ទុះនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានប្រសិទ្ធភាពរឹងមាំ និងជវភាព។** ចាប់តាំងពីក្របខណ្ឌគោលនយោបាយនេះត្រូវបានដាក់ឱ្យអនុវត្ត, ប្រព័ន្ធគាំពារសង្គមមានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញជាបន្តបន្ទាប់នូវកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមថ្មីៗ និងការកែលម្អកម្មវិធី និងរបបដែលបានអនុវត្តកន្លងមក ដែលក្នុងនោះ កម្ពុជាបានដាក់ឱ្យអនុវត្តវិធានការគាំពារសង្គមដែលមិនធ្លាប់មានកន្លងមក គឺការឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជា បានរ៉ាប់រងហិរញ្ញប្បទាន និងការគ្រប់គ្រងធាតុផ្សំនានានៃប្រព័ន្ធនេះ កាន់តែច្រើនជាងមុន ដូចជាកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ជាដើម។ ក្រុមប្រឹក្សាជាតិគាំពារសង្គម បានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួលជាមួយ តួអង្គពាក់ព័ន្ធនានា ដើម្បីជំរុញឱ្យមានសុខដុមនីយកម្ម និងសង្គតិភាពរវាងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម។



**ទោះជាយ៉ាងនេះក្តី ប្រព័ន្ធគាំពារសង្គមនៅតែមានចំណុចខ្វះខាតមួយចំនួន។** ការវាយតម្លៃលើប្រព័ន្ធនេះ ផ្តោតលើការគ្របដណ្តប់ ភាពពេញលេញនៃសេវា, ចីរភាពហិរញ្ញវត្ថុ, អភិបាលកិច្ច និងសិនិទ្ធភាព (Coherence )។ ចំណុចខ្វះខាតក្នុងផ្នែកនីមួយៗភាគច្រើន ជាការឆ្លុះបញ្ចាំងពីដំណាក់កាលចាប់ផ្តើមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមកម្ពុជា ប៉ុន្តែមិនបានធ្វើឱ្យថមថយក្នុងការសម្រេចបាននូវ សមិទ្ធផលនានាក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយនេះឡើយ។

**ការគ្របដណ្តប់៖** បើទោះជាប្រព័ន្ធគាំពារសង្គមមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ក្តី, ការកំណត់អត្តសញ្ញាណ និងការចុះបញ្ជីក្រុមប្រជាពលរដ្ឋគោលដៅចូលក្នុងកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវការការគិតគូរបន្ថែម។

បច្ចុប្បន្នប្រជាពលរដ្ឋជាច្រើននាក់ដែល “**មិនទាន់ទទួលបានការគ្របដណ្តប់**” នៅមិនទាន់បានទទួលការគាំពារពីកម្មវិធីជាតិជំនួយសង្គម ដែលផ្តោតលើក្រុមប្រជាជនគោលដៅ និងពីរបបសន្តិសុខសង្គមដែលផ្តោតលើអ្នកដែលមានការងារធ្វើជាប់លាប់។

**ភាពគ្រប់គ្រាន់៖ លើកលែងករណីវិជ្ជមានមួយចំនួន, ការកំណត់អំពីកម្រិតអត្ថប្រយោជន៍គួរត្រូវបានកែសម្រួល។** អត្ថប្រយោជន៍នៃប្រព័ន្ធជំនួយសង្គមនៅមានកម្រិតនៅឡើយ បើធៀបនឹងនិយាមអន្តរជាតិ។ ទោះជាយ៉ាងនេះក្តី, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ (CT-COVID) បង្ហាញពីភាពគ្រប់គ្រាន់នៃការផ្តល់ប្រាក់ឧបត្ថម្ភ បើធៀបនឹងនិយាមកម្មវិធីដែលធ្លាប់អនុវត្តកន្លងមក។ តាវកាលិកនៃរបបសន្តិសុខសង្គម ជាទូទៅមានកម្រិតសមស្របតាមកម្រិតអប្បរមានៃ និយាមអន្តរជាតិ បើទោះជាការធ្វើស្ថាប័នីយកម្មត្រូវបានគិតគូរ មួយចំនួននៅមានភាពចាំបាច់។



## រូបទី១: ចំណាយលើសេវាគាំពារសង្គម (មិនរាប់បញ្ចូលសេវាសុខភាព) គិតជាភាគរយនៃ ផ.ស.ស ឆ្នាំ២០២០។




**ចីរភាពហិរញ្ញវត្ថុ៖ វឌ្ឍនភាពដែលសម្រេចបាននៅមានកម្រិតបើធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងផែនការសកម្មភាពពាក់ព័ន្ធនឹងចីរភាពហិរញ្ញវត្ថុដោយការចំណាយលើប្រព័ន្ធនេះនៅមានកម្រិត។** ជារួម, ចំណាយលើប្រព័ន្ធគាំពារសង្គមនៅមានកម្រិតទាប បើធៀបនឹងថ្នាក់តំបន់។ ការឆ្លើយតបនៃប្រព័ន្ធគាំពារសង្គមចំពោះវិបត្តិកូវីដ-១៩ នាំឱ្យចំណាយកើនឡើងខ្ពស់ក្នុងកម្រិតដែលមិនធ្លាប់មានកន្លងមក បើទោះជាកម្មវិធីនេះអនុវត្តជាបណ្តោះអាសន្នក៏ដោយ (សូមមើលរូប-ទី១)។ ចំណាយប្រចាំឆ្នាំលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ១៩ (១,៣%-នៃផ.ស.ស) ច្រើនជាងចំណាយសរុបលើកម្មវិធីជំនួយសង្គម និងតាវកាលិក ប.ស.ស. សម្រាប់កម្មករនិយោជិតនៃវិស័យឯកជនដល់ទៅជាង ៤ ដង។ នៅពេលដែលប្រព័ន្ធនេះពង្រីកខ្លួនធំ ការពង្រឹងវិធានអភិបាលកិច្ចហិរញ្ញវត្ថុ ជាពិសេសដើម្បីធានាឱ្យបាននូវចីរភាពនៃមូលនិធិដែលបានពីការបង់ភាគទានពិតជាមានសារៈសំខាន់។



**អភិបាលកិច្ច៖ ចាំបាច់ត្រូវមានការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលគោលនយោបាយដើម្បីបង្កើនប្រសិទ្ធភាពការងារ។** កន្លងមក មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើនដូចជាការបង្កើតស្ថាប័នសម្របសម្រួល និងការធ្វើសុខដុមនីយកម្មនៃកម្មវិធីនានាជាដើម។ ទោះជាយ៉ាងនេះក្តី, ខណៈពេលដែលក្របខណ្ឌនេះ បានកំណត់យ៉ាងច្បាស់ពីស្ថាប័នដែលគួរដឹកនាំការងារសម្របសម្រួល ក្របខណ្ឌគោលនយោបាយនេះមិនបានកំណត់ឱ្យបានច្បាស់ ថាតើការសម្របសម្រួល គួរធ្វើឡើងដោយរបៀបណានោះឡើយ។ ការវាយតម្លៃនេះរកឃើញថា យន្តការដែលស្ថាប័ននានាអាចសម្រេចក្នុងការសម្របសម្រួលគោលនយោបាយអាចត្រូវបានកំណត់ឱ្យច្បាស់ ជាពិសេស ចាំបាច់ត្រូវមានការបែងចែករវាងការសម្របសម្រួលស្ថាប័ន និងការសម្របសម្រួលកម្រិតគោលនយោបាយ។

**សង្គតិភាព៖ បញ្ហាប្រឈមជារួមមួយនៃប្រព័ន្ធគាំពារសង្គម គឺភាពស៊ីសង្វាក់ក្នុងកម្រិតគោលនយោបាយ។** ខណៈពេលដែលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម បានជួយបង្កើនភាពស៊ីសង្វាក់គ្នានៃប្រព័ន្ធ, បញ្ហាប្រឈមសំខាន់មួយដែលត្រូវដោះស្រាយ គឺភាពដាច់ដោយឡែកពីគ្នានៃប្រព័ន្ធសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។ គំនិតផ្តួចផ្តើមជាច្រើនត្រូវបានអនុវត្ត ដើម្បីបង្កើនភាពស៊ីសង្វាក់គ្នា ប៉ុន្តែប្រព័ន្ធទាំងពីរនេះ ត្រូវបានយល់ឃើញ និងចាត់ទុកថាជាប្រព័ន្ធដាច់ពីគ្នា ទាំងក្នុងទិដ្ឋភាពគោលនយោបាយ និងទិដ្ឋភាពប្រតិបត្តិការ។ បញ្ហាទាំងនេះអាចមិនត្រូវបានគេមើលឃើញភ្លាមៗនោះ-ទេ យោងលើស្ថានភាពនៃប្រព័ន្ធគាំពារសង្គមនាពេលបច្ចុប្បន្ន ប៉ុន្តែនឹងស្តែងចេញឱ្យឃើញកាន់តែច្បាស់បន្តិចម្តងៗ នៅពេលដែលប្រព័ន្ធនេះ ពង្រីកវិសាលភាពគ្របដណ្តប់កាន់តែធំជាងមុន។ ផ្នែកថែទាំសុខភាពជាផ្នែកមួយដែលបង្ហាញឱ្យឃើញពីការខិតខំជំរុញឱ្យមានភាពស៊ីសង្វាក់គ្នានៅកម្រិតគោលនយោបាយ តាមរយៈការរៀបចំផែនទីបង្ហាញផ្លូវ ដើម្បីសម្រេចបានការគ្របដណ្តប់សុខភាពជាសកល។

រូបទី ២. ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា



# អនុសាសន៍រួម

ការវាយតម្លៃនេះអាចទាញសេចក្ដីសន្និដ្ឋានថា ការកែសម្រួលក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម នឹងផ្ដល់ជាប្រយោជន៍សម្រាប់តម្រង់ទិសដល់ការបន្តធ្វើឱ្យប្រព័ន្ធគាំពារសង្គម ដែលការវាយតម្លៃនេះបង្ហាញពីសក្ខីកម្ម នៃការអនុវត្តជោគជ័យនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃប្រព័ន្ធគាំពារសង្គម ព្រមទាំងមេរៀនដែលទទួលបានចាប់តាំងពីឆ្នាំ ២០១៦ មក រួមទាំងបទពិសោធន៍ឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ផងនោះ ជាមូលដ្ឋានសម្រាប់កំណត់ចក្ខុវិស័យនៃប្រព័ន្ធនេះ ក្នុងការបោះជំហានឆ្ពោះទៅមុខកាន់តែជាក់លាក់ និងជវភាព។ ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមត្រូវធ្វើឡើងជាជំហានៗ ដែលទាមទារឱ្យមានការពិចារណាយ៉ាងមធ្យ័តលើការកំណត់អាទិភាព ព្រមទាំងការផ្ដល់ហិរញ្ញប្បទានពាក់ព័ន្ធនានា។ ការវាយតម្លៃនេះបានផ្ដល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម (១) ទិសដៅរួមនៃគោលនយោបាយ (២) លក្ខណៈសំខាន់ៗនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមក្នុងដំណាក់កាលបន្ទាប់ (៣) បញ្ហាឆ្លងវិស័យ និង (៤) ទស្សនាទាន និងនិយមន័យ។

## ១. ទិសដៅរួមនៃគោលនយោបាយ

**មានការយល់ស្របជារួមថា ចំណុចសំខាន់នៃគោលនយោបាយ នឹងធ្វើឱ្យប្រព័ន្ធកាន់តែមានបរិយាបន្នតាមរយៈការពង្រីកការគ្របដណ្ដប់ និងអត្ថប្រយោជន៍ ដែលជាមូលដ្ឋានដ៏សំខាន់** ដើម្បីឱ្យប្រព័ន្ធគាំពារ-សង្គមអាចបំពេញសក្ដានុពល ក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាច្រើនដូចដែលបានលើកឡើងនៅក្នុងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម រួមមានការកាត់បន្ថយភាពក្រីក្រ និងវិសមភាព, ការលើកកម្ពស់លទ្ធផលផ្នែកថែទាំសុខភាព, ការគាំទ្រដល់ការអភិវឌ្ឍមូលធនមនុស្ស, ការ-បង្កើនការងារ និងផលិតភាព ព្រមទាំងការជំរុញកំណើនស្ថិរភាពសេដ្ឋកិច្ច។ អនុសាសន៍ពាក់ព័ន្ធនឹងទិសដៅគោលនយោបាយជារួមនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម រួមមាន៖

> បន្តអនុវត្តអភិក្រមមួយដែលមានពីរផ្នែក ដែលបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីបង្កើនបរិយាបន្ននៃប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

> បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រីកការគ្របដណ្ដប់ ដោយគួរបញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិ សម្រាប់ការជំរុញឱ្យចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

> បង្កើនកម្រិតវិនិយោគលើប្រព័ន្ធគាំពារសង្គមជាបន្តបន្ទាប់ ជាមួយនឹងការទទួលស្គាល់ថា ការបង្កើនការវិនិយោគជាបុរេលក្ខខណ្ឌ ដើម្បីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធ។

## ២. លក្ខណៈសំខាន់ៗនៃក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមក្នុងដំណាក់កាលបន្ទាប់

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមនឹងបំពេញតួនាទីសំខាន់ក្នុងការតម្រង់ទិស ដើម្បីសម្រេចបាននូវវឌ្ឍនភាព ស្របតាមទិសដៅគោលនយោបាយខាងលើ។ ការពង្រីកវិសាលភាពគ្របដណ្តប់ និងភាពពេញលេញនៃអត្ថប្រយោជន៍ និងការកៀរគរធនធានហិរញ្ញវត្ថុ នឹងត្រូវធ្វើឡើងជាជំហានៗ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមថ្មីគួរត្រូវបានរៀបចំ។ ក្របខណ្ឌពេលសម្រាប់រៀបចំក្របខណ្ឌ-គោលនយោបាយថ្មីអាចត្រូវបានកំណត់តាមបែបផែនផ្សេងៗគ្នា ប៉ុន្តែលក្ខណៈសំខាន់មួយគឺក្របខណ្ឌនេះ នឹងតម្រង់ទិសដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមក្នុងរយៈពេលវែង។ អនុសាសន៍សម្រាប់ក្របខណ្ឌគោលនយោបាយ រួមមាន៖

- តម្រង់ទិសក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ដោយផ្តោតលើអភិក្រមវដ្តជីវិត។ ដោយហេតុថា(ទី១) អភិក្រមវដ្តជីវិតឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីលក្ខណៈនៃហានិភ័យ និងភាពងាយរងគ្រោះនៅកម្ពុជា និង( ទី២ ) អភិក្រមនេះផ្តល់នូវអំណោយផល សម្រាប់កសាងប្រព័ន្ធគាំពារសង្គម ដែលអាចធានាបាននូវភាពស៊ីសង្វាក់គ្នារវាងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។
- រៀបចំផែនទីបង្ហាញផ្លូវ ដើម្បីពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសង្គម និងភាពគ្រប់គ្រាន់នៃអត្ថ-ប្រយោជន៍។ ផែនទីបង្ហាញផ្លូវទាំងនេះ គួរបញ្ចូលចក្ខុវិស័យនៃកិច្ចការពារពីហានិភ័យនីមួយៗ ក្នុងរយៈពេលពីមធ្យមទៅរយៈពេលវែង និងមាគ៌ាឈានទៅសម្រេចចក្ខុវិស័យនេះ។
- កែសម្រួល ឬរៀបចំយន្តការអភិបាលកិច្ច ដើម្បីគាំទ្រដល់ដំណើរការនៅកម្រិតគោលនយោបាយ និងកម្រិតប្រតិបត្តិការដើម្បីរៀបចំ និងតាមដានការអនុវត្តផែនទីបង្ហាញផ្លូវ ពាក់ព័ន្ធនឹងហានិភ័យ/ដំណាក់កាលនីមួយៗនៃវដ្តជីវិត។
- ញែកឱ្យដាច់រវាងការងារកំណត់ទិសដៅជាយុទ្ធសាស្ត្រ និងការកំណត់គោលនយោបាយ នៅកម្រិតប្រតិបត្តិករ ដែលការណ៍នេះ នឹងជួយឱ្យយន្តការសម្របសម្រួលកាន់តែមានប្រសិទ្ធភាព ដើម្បីសម្រេចភារកិច្ចសំខាន់ៗរបស់យន្តការនេះ។

## ៣. បញ្ហាឆ្លងវិស័យ

ការតភ្ជាប់រវាងវិស័យគាំពារសង្គម និងគោលនយោបាយនៃវិស័យផ្សេងទៀត ដែលក្នុងនោះរួមទាំងអន្តរ-ប្រតិបត្តិការនៃប្រព័ន្ធទិន្នន័យគួរត្រូវបានពង្រឹង។ កន្លងមកដោយមានសក្ខីកម្មដែលបង្ហាញពីកិច្ចសហប្រតិបត្តិការវិជ្ជមានរវាងវិស័យនីមួយៗ, ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម អាចនឹងផ្តល់នូវកាលានុវត្តភាពសម្រាប់កសាងកិច្ចសហប្រតិបត្តិការឱ្យកាន់តែបុរេសកម្មដែលការតភ្ជាប់ទាំងនេះ រួមមាន ការតភ្ជាប់ជាមួយគោលនយោបាយអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធគាំពារសង្គម, ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម, ប្រព័ន្ធពន្ធដារ, ប្រព័ន្ធចុះបញ្ជីនានា ព្រមទាំងសកម្មភាព ដែលពាក់ព័ន្ធនឹងការផ្តល់តាវកាលិក (ឧទាហរណ៍-ប្រព័ន្ធទូទាត់)។ ការតភ្ជាប់រវាងមូលដ្ឋានប្រព័ន្ធទិន្នន័យជាតិនានា អាចរួមចំណែកដល់ដំណើរនៃការជំរុញការចុះបញ្ជីក្នុងប្រព័ន្ធ និងកំណត់ពីលក្ខណៈវិនិច្ឆ័យថ្មីៗ ដើម្បីអាចទទួលបានកិច្ចគាំពារ (ដូចជា ការធ្វើតេស្តទៅលើកម្រិតជីវភាព (affluence test) ជាដើម។

## ៤. ទស្សនាទាន និងនិយមន័យ

ក្នុងការរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមដំណាក់កាលបន្ទាប់, ចំណុចមួយចំនួនដែលពាក់ព័ន្ធនឹងការកំណត់ទស្សនាទាន និងនិយមន័យគាំពារសង្គម អាចនឹងធ្វើការកែសម្រួលបន្ថែមទៀត ចំណុចទាំងនេះរួមមាន៖

> ពិចារណាលើការកែសម្រួលនិយមន័យនៃប្រព័ន្ធគាំពារសង្គមទាំងមូល ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីធាតុផ្សំ និងមុខងាររបស់វា។ និយមន័យនៃប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ក៏ចាំបាច់ត្រូវធ្វើការកែសម្រួលផងដែរ ដើម្បីឱ្យកាន់តែមានសង្គតិភាព។

> កំណត់ទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់ប្រព័ន្ធគាំពារសង្គម ដែលអាចជាជម្រើសមួយដែលកំណត់ច្បាស់លាស់ពីគោលនយោបាយ និងកម្មវិធីគាំពារសង្គម, គោលនយោបាយ និងសេវា ដែលមានភាពប្រទាក់ក្រឡាគ្នាព្រមទាំងលទ្ធផលផ្ទាល់ និងប្រយោល។

> កំណត់ឱ្យបានច្បាស់ថាផ្នែកណានៃគោលនយោបាយទីផ្សារការងារ និងការថែទាំសង្គម (social- care) មានជាប់ពាក់ព័ន្ធ និងស្ថិតក្រោមវិសាលភាពនៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា។

គាំពារ
សង្គម
កម្ពុជា

SOCIAL PROTECTION IN CAMBODIA